


កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY

ការិយាល័យទំនាក់ទំនង Tel: 023 662 41 41 ទូរសារ/ Fax: 023 72 66 17
ឆ្នាំទី១២ លេខ៣១០៩ ថ្ងៃអាទិត្យ-ច័ន្ទ ទី០៣-០៤ ខែមីនា ឆ្នាំ២០១៣ តម្លៃ ១០០០ រៀល






# ពិធីចុះអនុស្សរណៈយោគយល់គ្នានៅសាកលវិទ្យាល័យសៅស៍អ៊ីសថ៏អេយសៀ



*ពិធីចុះអនុស្សរណៈយោគយល់គ្នា*

**ខេត្តសៀមរាប :** នាថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៣ កន្លងទៅនេះ នៅសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ខេត្តសៀមរាប មានពិធីចុះអនុស្សរណៈយោគយល់គ្នារវាងសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ខេត្តសៀមរាប និងមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់កម្ពុជាដើម្បីផ្តល់ទឹកប្រាក់កម្ចីសំរាប់ការអប់រំដល់និស្សិត ក្រោមវត្តមានរបស់លោកសៀន សុវណ្ណា សាកលវិទ្យាធិការនៃសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ខេត្តសៀមរាប និងលោកឈី ឈិនហួ នាយកប្រតិបត្តិមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់កម្ពុជាដោយមានការចូលរួមពីអស់លោក លោកស្រីជាសាកលវិទ្យាធិការរង គណៈគ្រប់គ្រង សាស្ត្រាចារ្យ បុគ្គលិកក្រុមហ៊ុន និងសិស្សានុសិស្ស និស្សិតចូលរួមផងដែរ។

ក្នុងកិច្ចស្វាគមន៍របស់លោកសៀន សុវណ្ណា សាកលវិទ្យាធិការនៃសាកលវិទ្យាល័យក៏បានលើកឡើងថា ដោយពីមួយថ្ងៃទៅមួយថ្ងៃសាកលវិទ្យាល័សៅស៍អ៊ីសថ៍អេយសៀ ខេត្តសៀមរាប កាន់តែមានភាពល្បីល្បាញដែលសាកលវិទ្យាល័យឈានមុខគេដែលជាដៃគូវិនិយោគនៃការសិក្សាដ៏ល្អបំផុតសំរាប់អ្នកសិក្សាមកពីគ្រប់មជ្ឈដ្ឋាននៅកម្ពុជា។ លោកសាកលវិទ្យាធិការក៏បានគូសបញ្ជាក់ថា ក្រោមកិច្ចដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីបានធ្វើឱ្យប្រទេសកម្ពុជាយើងមានការអភិវឌ្ឍន៍លើគ្រប់វិស័យសំខាន់វិស័យអប់រំតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សាក្នុងការបណ្តុះ

ខិតខំប្រឹងប្រែងផងដែរពីថ្នាក់ដឹកនាំបុគ្គលិកសិក្សាដោយឈរលើបេសកកម្មឧត្តមវិស័យ និងគោលដៅឲ្យាស់លាស់នូវយុទ្ធសាស្ត្រសំខាន់ៗរបស់សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ខេត្តសៀមរាប ទៀតផង។

លោកសៀន សុវណ្ណា ក៏បានឱ្យដឹងទៀតថា សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ខេត្តសៀមរាប ត្រូវបានទទួលស្គាល់ពីសំណាក់ស្ថាប័នក្នុងនិងក្រៅប្រទេសហើយពេលនេះត្រូវបានចុះអនុស្សរណៈយោគយល់គ្នាក្នុងកិច្ចសហប្រតិបត្តិការជាមួយមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់កម្ពុជាក្នុងគោលបំណងជួយសម្រាលដល់ការសិក្សារបស់និស្សិតកំពុងជួបការលំបាកក្នុងការសិក្សា។ ក្នុងនោះដែរលោកក៏បានគូសបញ្ជាក់ថា ការផ្តល់ប្រាក់កម្ចីសំរាប់ការអប់រំនេះក្នុងការបង្កើនសមត្ថភាពបន្តការសិក្សារបស់និស្សិតក្នុងការធានាបាននូវនិរន្តរភាពក្នុងការអប់រំនៅសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ព្រមទាំងបានធ្វើការទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់កម្ពុជាក្នុងការផ្តល់ប្រាក់កម្ចីសំរាប់ការអប់រំដែលខ្វះខាតថវិកាបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា។ លោកក៏បានលើកផងដែរពីការធ្វើការកម្ចីប្រាក់នេះនិស្សិតមួយចំនួនមានលទ្ធភាពក្នុងការបំពេញកិច្ចការងារផងនិងសិក្សាផងដែលអាចទទួលកំរៃយកមកជួយក្នុងការកាត់រំលស់នូវកម្ចីនូវកម្ចីទឹកប្រាក់នេះបានហើយទាំងនិស្សិត សាស្ត្រាចារ្យត្រូវត្រៀមលក្ខណៈការធ្វើសមាហរណកម្មនៃសមាគមន៍អាស៊ាននាឆ្នាំ២០១៥ខាងមុខផង

លោកឈី ឈិនហួ នាយកប្រតិបត្តិមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់កម្ពុជាក៏បានសម្តែងនូវមោទនភាពខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការចុះអនុស្សរណៈយោគយល់គ្នារវាងមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់កម្ពុជានិងសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ខេត្តសៀមរាបធ្វើឱ្យនិស្សិតទទួលបានផលប្រយោជន៍ពីការកម្ចីប្រាក់សំរាប់ការអប់រំបន្តការសិក្សានៅឧត្តមសិក្សា។ លោកក៏បានឱ្យដឹងថា មីក្រូហិរញ្ញវត្ថុវីសិនហ្វាន់កម្ពុជាគឺជាផ្នែកមួយរបស់អង្គការទស្សនពិភពលោកដែលកន្លងមកបានជួយដល់ប្រជាជនក្រីក្រដោយមិនបានផ្តោតទៅលើការងារជំនួញមួយប៉ុណ្ណោះទេដោយមានទស្សនវិស័យផ្តោតទៅលើអនាគតកុមារនៅប្រទេសចំនួន៩ក្នុងតំបន់អាស៊ីសំខាន់លើការអប់រំ បណ្តុះបណ្តាល ធនធានមនុស្ស។ លោកឈី ឈិនហួ ក៏គូសបញ្ជាក់ថា សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ មានជំនាញផ្នែកអប់រំ បណ្តុះបណ្តាធនធានមនុស្សហើយក្រុមហ៊ុនវីសិនហ្វាន់កម្ពុជាមានជំនាញផ្តល់ប្រាក់កម្ចីសំរាប់សង្គមការអប់រំដោយកន្លងមកក្រុមហ៊ុនបានសហការជាមួយបណ្តាអង្គការនានាក្នុងនោះដោយផ្តោតឆ្ពោះទៅលើបញ្ហាអេដស៍។ ក្នុងនោះលោកក៏បានលើកនូវលក្ខខណ្ឌមួយចំនួនក្នុងការផ្តល់ប្រាក់កម្ចីសំរាប់ការអប់រំចំពោះនិស្សិតដែលគ្មានលទ្ធភាពក្នុងការបង់ថ្លៃសិក្សានៅថ្នាក់ឧត្តមសិក្សានោះក្រុមហ៊ុនបានផ្តល់ប្រាក់កម្ចី១០០ដុល្លារទៅដល់២០០០ដុល្លារដោយបង់រំលស់តាមរយៈសញ្ញាបត្រសិក្សានៅពេលបង់រំលស់អស់ទើបប្រគល់ជូននូវសញ្ញាបត្រជូនផងដែរ។ ម្យ៉ាងទៀតអត្ថប្រយោជន៍នៃកម្ចីនេះគឺទទួលបានអត្រាការប្រាក់ទាបទទួលបានប្រាក់កម្ចី១០០ភាគរយសំរាប់បង់ថ្លៃសិក្សានិង២០ភាគរយចំណាយលើសំភារៈសិក្សានិងទទួលបានសេវាកម្មប្រកបដោយភាពរាក់ទាក់និងមានឱកាសចុះកម្មសិក្សាជាបុគ្គលិកស្ម័គ្រចិត្តជាបុគ្គលិកពេញសិទ្ធិនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ទៀតផង។ ក្នុងនោះដែរក៏មានធ្វើការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាធ្វើការប្រគល់វត្ថុអនុស្សាវរីយ៍ព្រមទាំងថតរូបទុកជាអនុស្សាវរីយ៍ផងដែរ។